សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០២ លេខ ២៣៨ ចេញផ្សាយថ្ងៃ សៅរ៍ ទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៨

## សៀមបោករដ្ឋាភិបាល ហ៊ុន សែន បានរហូតក្នុងរឿងជម្លោះព្រំដែន



លោក ឆៀ បាញ់ ពេលជួបចរចាជាមួយមេទ័ពសៀមលើកដំបូង



ប្រាសាទព្រះវិហារជាកេរមរតកដ៏មានតម្លៃរបស់ប្រជាជាតិខ្មែរ



លោក ហោ ណាំហុង



លោក តេជ ប៊ុនណាក



ទាហានសៀមនៅតែកាន់កាប់ច្រកចេញចូលប្រាសាទតាមាន់ជំដែល

ដោយ : គ.អរពិន្ទ

ក្នុងស្ថានភាពដែលបញ្ហាប្រឈមមុខដាក់គ្នា រវាងកងទាហានសៀមឈ្លានពានតទល់នឹងទាហានខ្មែរនៅតាមខ្សែបន្ទាត់ព្រំដែនពុំមានការធូរស្រាលនៅឡើយនោះ បញ្ហានយោបាយវឹកវរនៅប្រទេសសៀមក៏កាន់តែពុះកញ្ជ្រោលឡើង។ រឿងនេះបណ្តាលឱ្យមានការគិតខ្វល់ដល់វាសនានៃទឹកដីកម្ពុជានៅ

តទៅទំព័រ៤ ម

## សុន ឆ័យ ថា ខៀវ កាញារីទ្ធ និយាយស្តីមិនស័ក្តិសមជាអ្នកចេះដឹងសោះ



លោក សុន ឆ័យ អ្នកនាំពាក្យគណបក្សសមរង្ស៊ី



លោក ខៀវ កាញារីទ្ធ

ដោយ : សុរ្យាវរីយ៍

អ្នកនាំពាក្យ គណបក្សសមរង្ស៊ី លោក*សុន ឆ័យ* បានរិះគន់អ្នកនាំពាក្យ គណបក្សប្រជាជនលោក*ខៀវ កាញារីទ្ធ* ថា និយាយស្តីមិនស័ក្តិសម ជាអ្នកចេះដឹងទេ ។ ការវាយប្រហារដោយពាក្យសម្តី គ្រោតគ្រាត

តទៅទំព័រ៤ ស

## មេធាវី ជូង ជូងី បំភ្លឺពីករណីបង់ពន្ធក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ



លោកមេធាវី ជូង ជូងី




ប្រជាពលរដ្ឋនៅបឹងកក់ពេលតវ៉ានៅសាលាក្រុងលើកដំបូង

ដោយ : យុទ្ធ ពន្យ

លោកមេធាវី *ជូង ជូងី* បានបំភ្លឺយ៉ាងច្បាស់លាស់កាលពីព្រឹកថ្ងៃសុក្រ ទី៥ ខែកញ្ញា ឆ្នាំ ២០០៨មិ្សលមិញអំពីរឿងបង់ពន្ធក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការដោយលោកបានបញ្ជាក់ថា លោកមានចំណុចសំខាន់៧

តទៅទំព័រ២ ឈ

## កុល សុខុម និងតារាភាពយន្តពិភពលោក ជេម ស្ប៊ែន ០០៧វិនិយោគរួមគ្នាធ្វើឱ្យកក្រើកអាស៊ី



លោកស្រី កុល សុខុម និងតារាភាពយន្ត ជេម ស្ប៊ែន ហៅ ០០៧

ដោយ: សច្ចះ

តារាភាពយន្តហូលីវូដ ជនជាតិអង់គ្លេសដ៏ល្បីឈ្មោះនៅលើពិភពលោកម្នាក់ បានមកបំពេញទស្សនកិច្ច នៅក្នុងប្រទេសកម្ពុជា ចំនួន២សប្តាហ៍ ។ ដំណើរទស្សនកិច្ចជាលើកដំបូងនេះគឺផ្តោតសំខាន់ ទៅលើតំបន់ទេសចរណ៍ជាច្រើននៅក្នុង

តទៅទំព័រ៣ គ

## មន្ត្រីហ្វ៊ុនស៊ិនប៉ិចដែលធ្វើជាឯកអគ្គរាជទូតនៅបណ្តាប្រទេសចំនួន៧នឹងត្រូវផ្លាស់ប្តូរម៉ដ្ឋដូចអាចម៍ទីទុយ



លោក លឺ ឡាយស្រេង អនុប្រធានទី១គណបក្សហ្វ៊ុនស៊ិនប៉ិច



លោកឧត្តម ណាន់ ស៊ី



លោកឧត្តម ពូ សុធីរះ

ដោយ : ជ.ឧត្តម

ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាដែលនៅប្រចាំការក្នុងបណ្តាប្រទេសចំនួន៧ និងសុទ្ធសឹងតែជាមន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិចនោះ ត្រូវបានរដ្ឋាភិបាលលោក *ហ៊ុន សែន* បង្ហើបឱ្យដឹងថា នឹងធ្វើការផ្លាស់ប្តូរម៉ដ្ឋដូចអាចម៍ទីទុយហើយ បន្ទាប់ពីរដ្ឋាភិបាលថ្មី អាណត្តិទី៤ លេចចេញជារូបរាងនៅចុងខែកញ្ញា

តទៅទំព័រ២ ន

## ភ្នំពេញជាទីក្រុងល្បែងនិងជាជំរកក្មេងអន្ធពាល

ដោយ : រតនៈ

ទីក្រុងភ្នំពេញសព្វថ្ងៃ សំបូរទៅដោយ បនល្បែងកាស៊ីណូជាទ្រង់ទ្រាយធំ ជាទ្រង់ទ្រាយតូច នៅតាមក្លឹបកំសាន្ត សណ្ឋាគារ និងនៅតាមលំនៅឋាន ។ ចំពោះបនល្បែងនៅសណ្ឋាគារក្លឹបកំសាន្តនោះ ត្រូវបានគេដឹងថាកន្លែងខ្លះមានច្បាប់អនុញ្ញាតត្រឹមត្រូវ គឺអ្នកលេងទោះបីជា

តទៅទំព័រ៣ ហ

## អ្នកក្រុងព្រះសីហនុខ្លាចឈ្មោះ ស្បោង សារ៉ាត ជាងខ្លាច ហ៊ុន សែន



លោក ស្បោង សារ៉ាត



នាយករដ្ឋមន្ត្រីល្មោភនឹងអំណាចមិនស្គាល់ស្កប់ឈ្មោះ ហ៊ុន សែន

ដោយ : វិសាល

នៅពេលដែលប្រជាពលរដ្ឋក្នុងក្រុងព្រះសីហនុដឹងថាលោក *ស្បោង សារ៉ាត* បានឡើងធ្វើជាចៅហ្វាយក្រុងព្រះសីហនុយ៉ាងពេញមុខហើយនោះ គឺម្នាក់ៗហាក់ដូចរួញអស់សរសៃរលីង ព្រោះកន្លងមកប្រជាពលរដ្ឋខ្លាច

តទៅទំព័រ២ ជ

ស្រូវទុំ កំរងកែវ

ភោជនីយដ្ឋាន **កំរងកែវ** អតីតភោជនីយដ្ឋាន **ស្រូវទុំ** ឥឡូវនេះបានបើកឡើងវិញហើយ ដោយប្តូរឈ្មោះថា **កំរងកែវ** ដោយប្តូរទាំងចៅកែ ។

លោក មាស គន្ធី ដែលជាអតីតចៅកែភោជនីយដ្ឋាន **ស្រូវទុំ** ត្រូវបានផ្លាស់ប្តូរដោយចៅកែថ្មីដែលមានជំនាញពិសេសល្អលើសចៅកែចាស់ (ស្រូវទុំ) ទ្វេដង ពីព្រោះចៅកែថ្មី និងចុងភៅសុទ្ធតែមានបទពិសោធយូរឆ្នាំ និងមានជំនាញច្បាស់លាស់ ។

អាស្រ័យហេតុនេះ សូមអញ្ជើញភ្ញៀវទាំងអស់មកភ្លក្សរសជាតិដែលជាស្នាដៃរបស់ចៅកែ និងចុងភៅថ្មី និងមានការរៀបចំយ៉ាងពិសេសសម្រាប់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកពិសានៅភោជនីយដ្ឋានយើងខ្ញុំ ។

**បញ្ជាក់** : ចំពោះភ្ញៀវដែលអញ្ជើញមកពិសានៅភោជនីយដ្ឋាន **កំរងកែវ** យើងខ្ញុំដោយភ្ជាប់ជាមួយនឹងប័ណ្ណជូនដំណឹងក្នុងសារព័ត៌មានខ្មែរម្ចាស់ស្រុកនេះ យើងខ្ញុំនឹងបញ្ចុះតម្លៃជូន១០% ។

អាស័យដ្ឋាន ផ្ទះលេខ៤២ ផ្លូវ២៨៩ កែងសាលាទួលគោក "ពៅអ៊ុំ"

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លឹម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្អំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បៀត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

ទីតាំងផ្ទះលេខ២០៧៧ **ហោ លឹម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្តាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616, 012 801 863, 016 719 613

*បរិយាយថ្ងៃនេះ*

## មាសជាតិជាង១២តោនពេជ្រជាង២គីឡូក្រាម នរណាយកទៅណា ?

ដោយ : ហង្ស ប្រាថ្នា

អតីតនាយករដ្ឋមន្ត្រីកម្ពុជាកាលដំនាន់កងទ័ពយួនចូលលុកលុយកម្ពុជា ហើយថែមទាំងជាប្រធាននៃគណបក្សប្រជាជនបដិវត្តកម្ពុជា ជាឈ្មោះដើមគណបក្សប្រជាជនសព្វថ្ងៃ បាននិយាយកាលពីពេលថ្មីៗនេះថា ពេលគាត់បាននាំទាហានយួនចូលវាយរំលំរបប ប៉ុល ពត នៅឆ្នាំ១៩៧៩នោះ ក៏បានឃើញមាសពេជ្ររបស់ជាតិយ៉ាងច្រើន។ លោក ប៉ែន សុវណ្ណ

តទៅទំព័រ៤ ក

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០២**
Tel: 012 850 690 / 017 360 678 , Fax: 023 987 411

**តមកពីទំព័រ១ ឈ**

ចំនួន២ដែលត្រូវបំភ្លឺទៅប្រជាពលរដ្ឋ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដើម្បីកុំឱ្យមានការយល់ច្រឡំតទៅទៀត។

លោកមេធាវីរូបនេះបានអត្ថាធិប្បាយថា "*ចំណុចទី១ ការបង់ពន្ធនេះមិនមែនជាការទាមទាររបស់តុលាការទេ។ ហើយតុលាការក៏មិនបានទាមទារអ្វីដែរ តែវាជាតម្រូវការរបស់ច្បាប់ដែលច្បាប់ខ្មែរយើងគឺគ្រប់ពាក្យបណ្តឹងត្រូវតែបង់ពន្ធដើម្បីឱ្យតុលាការអាចយកទៅចាត់ការតាមច្បាប់បាន*"។

ទាក់ទិនទៅនឹងចំណុចទី២ លោកមេធាវី *ជូង ជូឌី* បានបញ្ជាក់ច្បាស់ថា "*ក្នុងករណីបឹងកក់នេះ មិនមែនប្រជាពលរដ្ឋត្រូវបង់ពន្ធ៣៩,៥លានដុល្លារសហរដ្ឋអាមេរិកដូចការផ្សាយក្នុងទំព័រសារព័ត៌មានជាតិ និងអន្តរជាតិកន្លងមកនោះទេ។ ហើយតាមពិតទៅ គឺត្រូវគិតពន្ធលើទឹកប្រាក់៣៩,៥លានដុល្លារ ហើយបើតាមការគិតក្រៅផ្លូវការរបស់ខ្ញុំវិញ គឺប្រាក់ដែលត្រូវបង់ពន្ធដើម្បីដាក់ពាក្យបណ្តឹងករណីបឹងកក់នេះប្រហែលជា១៦០លានរៀលតែប៉ុណ្ណោះ សម្រាប់ឱ្យតុលាការយករឿងក្តីនេះទៅចាត់ការតាមផ្លូវច្បាប់*"។

ពាក់ព័ន្ធនឹងសំណួរ "*ខ្មែរម្ចាស់ស្រុក*" ដែលថា មានហេតុផលអ្វីខ្លះទៅតាមផ្លូវច្បាប់ដែលតម្រូវឱ្យដើមបណ្តឹងបង់ពន្ធជូនតុលាការនោះ? លោកមេធាវី *ជូង ជូឌី* បានមានប្រសាសន៍ថា "*ត្រង់កន្លែងនេះគឺមានចន្លោះចំហនៃច្បាប់បន្តិចពីព្រោះប្រជាពលរដ្ឋរស់នៅក្នុងតំបន់បឹងកក់នេះមិនមែនជាភាគីក្នុងកិច្ចសន្យាទេ។ ហើយអ្នកដែលចុះកិច្ចសន្យានោះ គឺសាលាក្រុងភ្នំពេញ និងក្រុមហ៊ុនស៊ូកាគូអ៊ីន, រីឯប្រជាពលរដ្ឋនៅតំបន់បឹងកក់គ្រាន់តែជាអ្នករងគ្រោះដោយសារតែកិច្ចសន្យាហ្នឹង*"។

លោក *ជូង ជូឌី* មេធាវីការពារក្តីឱ្យជនរងគ្រោះនៅតំបន់បឹងកក់បានឱ្យយើងដឹងបន្ថែមទៀតថា "*តាមផ្លូវច្បាប់កាលណាប្រជាពលរដ្ឋជាអ្នករងគ្រោះដោយសារសាលាក្រុងយកតំបន់បឹងកក់នេះទៅជួលឱ្យក្រុមហ៊ុនឯកជនគឺប្រជាពលរដ្ឋគាត់មានសិទ្ធិប្តឹងតវ៉ាប្តឹងបដិសេធចំពោះកិច្ចសន្យានេះ*"។

លោកមេធាវីបានថ្លែងឱ្យដឹងទៀតថា "*ប្រសិនបើផ្លូវច្បាប់តម្រូវឱ្យប្រជាពលរដ្ឋបង់ពន្ធនោះ គឺជារឿងអយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋហើយ ព្រោះប្រជាពលរដ្ឋជាអ្នករងគ្រោះដោយសារតែការចុះកិច្ចសន្យានោះ លុះដល់ប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងបែរជាផ្លូវច្បាប់តម្រូវឱ្យពួកគាត់បង់ពន្ធទៅវិញ*"។

យ៉ាងណាក៏ដោយ លោកមេធាវី *ជូង ជូឌី* បានគូសបញ្ជាក់ថា "*តាមផ្លូវច្បាប់ គឺប្រជាពលរដ្ឋត្រូវតែបង់ពន្ធ។ ប៉ុន្តែក្នុងនាមខ្ញុំជាមេធាវី ដែលតំណាងឱ្យប្រជាពលរដ្ឋ ខ្ញុំនឹងព្យាយាមរិះរកគ្រប់វិធីដែលអាចទៅរួចដើម្បីធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋមិនចាំបាច់បង់ពន្ធ ហើយទាមទារឱ្យតុលាការទទួលយកពាក្យបណ្តឹងប្រជាពលរដ្ឋទៅដោះស្រាយ*"។

គួររំលឹកថា ដោយសារតែសារព័ត៌មានជាតិ និងអន្តរជាតិបានដកស្រង់សម្តីលោកមេធាវី *ជូង ជូឌី* ទៅសរសេរខុសថាប្រជាពលរដ្ឋត្រូវបង់ពន្ធរាប់លានដុល្លារទៅឱ្យតុលាការក្នុងការដាក់ពាក្យបណ្តឹងនោះ ទើបលោកមេធាវីរូបនេះសម្រេចធ្វើការបំភ្លឺជាសាធារណៈតាមរយៈសារព័ត៌មាន "*ខ្មែរម្ចាស់ស្រុក*" តែម្តង។

លោកមេធាវីបានពន្យល់ដើម្បីកុំឱ្យមានការភាន់ច្រឡំតទៅទៀតថា "*ការបង់ពន្ធនេះមិនមែនជាការទាមទាររបស់តុលាការទេ ហើយក៏មិនមែនជាការកំណត់របស់តុលាការថាត្រូវតែបង់ពន្ធដែរពោលគឺច្បាប់ជាអ្នកកំណត់ថា រាល់ពាក្យបណ្តឹងដើម្បីអាចប្តឹងដាក់ចូលទៅតុលាការបាន គឺអ្នកប្តឹងត្រូវបង់ពន្ធ។ បានសេចក្តីថា នេះជាការកំណត់ដោយច្បាប់*"។

ទន្ទឹមនេះ លោកមេធាវីបានបញ្ជាក់ច្បាស់ជាចុងក្រោយថា "*ចំនួនទឹកប្រាក់ដែលត្រូវបង់ពន្ធក្នុងករណីដាក់ពាក្យបណ្តឹងរឿងបឹងកក់នេះគឺមិនមែនមានចំនួន៣៩,៥លានដុល្លារដូចការចុះផ្សាយរបស់សារព័ត៌មាននានានោះទេ។ ហើយបើតាមខ្ញុំគិតក្រៅផ្លូវការវិញ គឺដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការបានប្រជាពលរដ្ឋនៅតំបន់បឹងកក់ដែលជាដើមបណ្តឹងត្រូវបង់ពន្ធទៅលើទឹកប្រាក់ចំនួន៣៩,៥លានដុល្លារហ្នឹង គឺប្រហែលជា១៦០លានរៀលលុយខ្មែរតែប៉ុណ្ណោះ*"។

ជាមួយគ្នានេះដែរ លោកមេធាវី *ជូង ជូឌី* បានមានប្រសាសន៍បញ្ជាក់បន្ថែមថា ប្រសិនបើមានចម្ងល់អ្វីមួយពីចំនួនទឹកប្រាក់ដែលត្រូវបង់ពន្ធជូនតុលាការនេះ គឺអ្នកសារព័ត៌មានអាចសាកសួរលោកដោយផ្ទាល់ក៏បាន ព្រោះការសរសេរខុសដោយសារតែការគិតមិនដល់នេះ អាចធ្វើឱ្យសាធារណៈជនមានការយល់ច្រឡំអំពីផ្លូវច្បាប់។

ខាងក្រោមនេះគឺជាសេចក្តីបំភ្លឺរបស់លោកមេធាវី *ជូង ជូឌី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យច្បាប់ស៊ីលា**
LAW OFFICE CILA
Tel: 011 866 104 / 012 290 678

ភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៨

**ខ្ញុំមេធាវី ជូង ជូឌី សុំឱ្យមានការកែតម្រូវការចុះផ្សាយរបស់សារព័ត៌មានជាតិ និងអន្តរជាតិកន្លងមក ពាក់ព័ន្ធនឹងការបង់ពន្ធដាក់ពាក្យបណ្តឹងទៅសាលាដំបូងក្រុងភ្នំពេញ ក្នុងករណីបឹងកក់**

១- ក្នុងការដាក់ពាក្យបណ្តឹងទាមទារមោឃភាពកិច្ចសន្យាទៅសាលាដំបូងក្រុងភ្នំពេញគឺសាលាដំបូងក្រុងភ្នំពេញមិនបានទាមទារឬក៏មិនបានតម្រូវឱ្យប្រជាពលរដ្ឋបង់ពន្ធចំនួន៣៩,៥លានដុល្លារនោះទេ។ ការបង់ពន្ធដាក់ពាក្យបណ្តឹង គឺគោរពតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងផ្អែកលើតារាងនៃពន្ធដាក់ពាក្យបណ្តឹងដែលរៀបចំដោយក្រសួងយុត្តិធម៌។

២- ចំនួនប្រាក់ដែលត្រូវបង់ពន្ធដាក់ពាក្យបណ្តឹង ក្នុងករណីបឹងកក់ មិនមែនចំនួន៣៩,៥លានដុល្លារទេ គឺត្រូវបង់ពន្ធលើប្រាក់ចំនួន៣៩,៥លានដុល្លារ។ បើតាមតួលេខគិតក្រៅផ្លូវការ ពន្ធដាក់ពាក្យបណ្តឹងទាមទារមោឃភាពកិច្ចសន្យាក្នុងករណីបឹងកក់ គឺប្រហែល១៦០លានរៀលតែប៉ុណ្ណោះ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ សារព័ត៌មានជាតិ និងអន្តរជាតិមេត្តាជ្រាបជាព័ត៌មាន។

**តមកពីទំព័រ១ ៩**

ឈ្មោះ *ស្បោង សារ៉ាត* នេះជាងខ្លាច *ហ៊ុន សែន* ទៅទៀត។

មានហេតុផលអ្វីខ្លះដែលធ្វើឱ្យប្រជាពលរដ្ឋមានការខ្លាចរអាលោក *ស្បោង សារ៉ាត* យ៉ាងដូច្នេះ? ប្រជាពលរដ្ឋបានឱ្យយើងដឹងថា តាំងពីរដ្ឋាភិបាលកញ្ចប់ *ហ៊ុន សែន* បញ្ជូនលោក *ស្បោង សារ៉ាត* ពីខេត្តព្រៃវែងមកធ្វើជាអភិបាលរងក្រុងព្រះសីហនុពេលណាមកគឺអ្វីៗដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវបានរលាយរលត់ជាបន្តបន្ទាប់។

មិនតែប៉ុណ្ណោះប្រពន្ធលោក *ស្បោង សារ៉ាត* ក៏មានអំណាចមិនធម្មតាដែរ។ ហើយពាក់ព័ន្ធនឹងការដោះដូរទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅក្រុងព្រះសីហនុកន្លងមកនោះ ក៏សុទ្ធតែជាស្នាដៃដ៏ឆ្នើមរបស់ប្រពន្ធ *ស្បោង សារ៉ាត* និងបក្ខពួកទាំងអស់។

យោងតាមហេតុផលនេះហើយ ទើបបានជាប្រជាពលរដ្ឋនៅក្រុងព្រះសីហនុថ្លែងដោយហួសចិត្តប្រាប់ "*ខ្មែរម្ចាស់ស្រុក*" ថា មហាតេជោ *ហ៊ុន សែន* ពិតជាយ៉ាប់មែនទែន តែងតាំងនរណាមិនតែងតាំង បែរជាមកតែងតាំងឱ្ខាត្រី *ស្បោងសារ៉ាត* ដែលជាមេកំពូលល្បិចឱ្យធ្វើជាចៅហ្វាយក្រុងព្រះសីហនុទៅវិញ។ ហើយថា ការតែងតាំងឱ្ខាត្រី *ស្បោង សារ៉ាត* នៅពេលនេះ គឺដូចបំពាក់ស្លាបឱ្យប្រពន្ធ និងកូនប្រសាររបស់ *ស្បោង សារ៉ាត* ឱ្យកាន់តែឡើងចាងអុងអាត់ពេញក្រុងព្រះសីហនុថែមទៀត។

សួរថានៅពេលដែលលោក *ស្បោង សារ៉ាត* មកធ្វើជាអភិបាលរងក្រុងព្រះសីហនុតើមានការរីកចំរើនអ្វីខ្លះ? ប្រសិនបើប្រជាពលរដ្ឋនៅក្រុងព្រះសីហនុមិនយល់ច្រឡំទេ គឺលោក *ស្បោង សារ៉ាត* រីកចំរើនតែទ្រព្យសម្បត្តិផ្ទាល់ខ្លួនប៉ុណ្ណោះ។ ហើយសូម្បីតែនៅកាន់តំណែងជាអភិបាលរងក្រុងព្រះសីហនុក្រោមលោក *សាយ ហាក់* មួយថ្នាក់ក្តី ក៏លោក *ស្បោង សារ៉ាត* នៅតែពើងទ្រូងយកក្បាលទល់មេយ៉ាងអុងបីដែរ។

តាមពិតទៅប្រជាពលរដ្ឋភាគច្រើននៅក្រុងព្រះសីហនុមិនសប្បាយចិត្តនឹងការតែងតាំងរបស់រដ្ឋាភិបាល *ហ៊ុន សែន* ចំពោះលោក *ស្បោង សារ៉ាត* ម្នាក់នេះទេ ព្រោះជាទូទៅគេបានមើលឃើញថា មិនទាន់ធ្វើជាចៅហ្វាយក្រុងព្រះសីហនុផង លោក *ស្បោង សារ៉ាត* និងក្រុមគ្រួសារបំផ្លាញស្ទើររលាយរលត់នូវអចលទ្រព្យរបស់រដ្ឋរបស់ជាតិទៅហើយ ទំរាំបើធ្វើចៅហ្វាយក្រុងពេញមុខដូចថ្មីៗនេះទៀត តើក្រុងព្រះសីហនុនៅសល់អ្វី?

គេថាលោក *ស្បោងសារ៉ាត* នៅពីក្រោយខ្នងប្រពន្ធគាត់ជានិច្ច រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋនៅក្រុងព្រះសីហនុដែលកន្លងមកត្រូវបានគេរាយការណ៍មកថា អចលនទ្រព្យរបស់រដ្ឋជាច្រើនកន្លែងនៅក្រុងព្រះសីហនុត្រូវបានវិនាសអន្តរាយដោយសារស្នាដៃយ៉ាងប៉ិនប្រសប់របស់ប្រពន្ធជាទីស្រឡាញ់នៃលោក *ស្បោង សារ៉ាត* មេគណបក្សប្រជាជនប្រចាំក្រុងព្រះសីហនុ និងជាចៅហ្វាយរងទីក្រុងឆ្នេរសមុទ្រនេះស្ទើរតែរលាយរលត់អស់ទៅហើយ។

ប្រភពព័ត៌មានពីក្រុងព្រះសីហនុបានឱ្យយើងដឹងថាប្រពន្ធលោក *ស្បោង សារ៉ាត* និងកូនចៅគាត់ពិតជាមិនធម្មតានោះទេ ព្រោះចាប់តាំងពីលោក *ស្បោង សារ៉ាត* បានទៅធ្វើជាចៅហ្វាយរងក្រុងព្រះសីហនុមក គឺប្រពន្ធរបស់លោកឆ្លាតក្នុងរឿងរត់ការលក់ដូរទ្រព្យសម្បត្តិរដ្ឋស្ទើរតែរកលេខដាក់គ្មានតែម្តង។

ក្នុងនោះប្រភពព័ត៌មានដដែលបានលាតត្រដាងថា ទីតាំងមហោស្រពមួយកន្លែងដែលស្ថិតនៅចំកណ្តាលបេះដូងក្រុងព្រះសីហនុ ដែលមានទំហំប្រមាណជិត៣ហិកតា ត្រូវបានប្រពន្ធលោក *ស្បោង សារ៉ាត* រត់ការរកម៉ូយលក់បានចំណេញយ៉ាងកប់ក្តោង ពោលគឺគាត់ដោះដូរពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទាំងមិនខ្ចីបង់ពន្ធ៤ភាគរយជូនរដ្ឋថែមទៀតផង។

យោងតាមមន្ត្រីជំនាញមួយរូបនៅក្រុងព្រះសីហនុបានឱ្យដឹងថា "*គ្រាន់តែប្រាក់ពន្ធ៤ភាគ*

**តទៅទំព័រ៣ ៩**

**តមកពីទំព័រ១ ន**

ឆ្នាំ២០០៨នេះ។

សេចក្តីរាយការណ៍ព័ត៌មានបានឱ្យដឹងថា ប្រសិនបើមហិច្ឆតារបស់គណបក្សប្រជាជនក្នុងការបង្កើតរដ្ឋសភាកញ្ចប់ និងរដ្ឋាភិបាលកញ្ចប់បានសម្រេចដូចបំណងមែននោះ គឺហ៊្វុនស៊ិនប៉ិចនៅសេសសល់តែតំណែងបន្តិចបន្តួច និងគ្មានអំណាចអ្វីទាំងអស់។

ផ្អែកតាមប្រភពបានលើកឡើងថា បណ្តាប្រទេសដែលនឹងមានការផ្លាស់ប្តូរឯកអគ្គរាជទូតកម្ពុជាថ្មីដើម្បីទៅជំនួសឯកអគ្គរាជទូតចាស់ត្រូវចេញពីតំណែងនោះមានដូចជា សហរដ្ឋអាមេរិក, ជប៉ុន, អូស្ត្រាលី, ភូមា, ប្រ៊ុយណេ, ម៉ាឡេស៊ី និងប្រទេសគូវ៉ែត។

ប្រភពដដែលនេះបានបន្តទៀតថា ភាគច្រើននៃឯកអគ្គរាជទូតកម្ពុជាដែលត្រូវធ្វើការផ្លាស់ប្តូរនោះ គឺជាឯកអគ្គរាជទូតមកពីភាគីហ៊្វុនស៊ិនប៉ិចស្ថិតក្នុងរដ្ឋាភិបាលចម្រុះកញ្ចប់អាណត្តិទី៣ កន្លងទៅ។

លោក *ស៊ិន ប៊ុនធឿន* អ្នកនាំពាក្យក្រសួងការបរទេសបានថ្លែងប្រាប់បណ្តាញព័ត៌មាន (វិទ្យុអាស៊ីសេរី) ថា "*ប្រទេសខ្លះមានទូតជាមន្ត្រីហ៊្វុនស៊ិនប៉ិចមែន តែគាត់ត្រូវចប់អាណត្តិ*"។

ប្រភពស្និទ្ធនឹងក្រសួងការបរទេសបានបង្ហើបឱ្យដឹងថា ឯកសារសម្រាប់ផ្លាស់ប្តូរឯកអគ្គរាជទូតកម្ពុជាចំនួន៧រូបពីបណ្តាប្រទេសទាំង៧ដូចបានរៀបរាប់ខាងលើនេះ ត្រូវបានរៀបចំរួចជាស្រេច ពោលគឺរង់ចាំតែការដាក់ថ្វាយព្រះមហាក្សត្រសម្តេចព្រះបរមនាថ *នរោត្តម សីហមុនី* ឡាយព្រះហស្ថលេខាសម្រេចជាចុងក្រោយប៉ុណ្ណោះ។

នេះគឺជាព័ត៌មានដ៏ថ្មីស្រឡាងបំផុតបន្ទាប់ពីមន្ត្រីជាន់ខ្ពស់របស់គណបក្សហ៊្វុនស៊ិនប៉ិចមួយរូប គឺលោក *សាយ ហាក់* នៅក្រុងព្រះសីហនុត្រូវបានផ្លាស់ប្តូរយ៉ាងស្លូនស្លោ កាលពីថ្ងៃទី០៤ ខែកញ្ញា កន្លងទៅ ក្រោមការរិះគន់យ៉ាងកងរំពងពីសំណាក់ប្រជាពលរដ្ឋនៅទូទាំងក្រុងព្រះសីហនុ។

ទាក់ទិននឹងពាក្យថា "*កូតាគណបក្សហ៊្វុនស៊ិនប៉ិច*" ត្រូវបានលោក *លី ឡាយស្រេង* អនុប្រធានទី១ នៃគណបក្សហ៊្វុនស៊ិនប៉ិចមានប្រសាសន៍ពន្យល់ថា "*សម្រាប់រដ្ឋាភិបាលថ្មីដែលគណបក្សប្រជាជនកម្ពុជាគ្រោងនឹងបង្កើតនៅពេលខាងមុខនេះ គឺជាកម្មសិទ្ធិរបស់គណបក្សប្រជាជនកម្ពុជាទាំងអស់។ អញ្ចឹងទេ គណបក្សហ៊្វុនស៊ិនប៉ិចគ្មានកូតា ឬភាគហ៊ុនអ្វីទេនៅក្នុងរដ្ឋាភិបាលថ្មីនោះ*"។

លោក *លី ឡាយស្រេង* ដែលមជ្ឈដ្ឋានជាទូទៅទទួលស្គាល់ថា ជាព្រឹទ្ធបុរសមួយរូបដែលចូលចិត្តតែនិយាយត្រង់ៗ ដោយគ្មានលាក់លៀមនោះបានមានប្រសាសន៍បន្តទៀតថា "*ឥឡូវនេះវាអត់មានកូតាស្អីទៀតទេហើយបើយើងនិយាយពីរឿងកូតាវិញ គឺទាល់តែយើងទៅចរចាគ្នា ដូចជារឿងរកស៊ីចែកចំណេញគ្នា។កូតាមានន័យថាចែកគ្នាជាភាគរយ ដូចជាហ៊្វុនស៊ិនប៉ិចប៉ុន្មានភាគរយ, គណបក្សប្រជាជនប៉ុន្មានភាគរយអញ្ចឹងទៅ។ ឥឡូវគណបក្សប្រជាជនគេមិនត្រូវការភាគរយផងពីព្រោះគេជាម្ចាស់ក្រុមហ៊ុនមួយរយភាគរយទៅហើយ ដូច្នេះកូតាវាអស់សុពលភាពហើយ*"។

លោក *លី ឡាយស្រេង* បានឱ្យបណ្តាញព័ត៌មានដឹងថា តាមរយៈនៃការយោគយល់គ្នារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចក្នុងការចងសម្ព័ន្ធភាពធ្វើជារដ្ឋាភិបាលចម្រុះនាពេលកន្លងមកនោះ គឺគេឱ្យមន្ត្រីហ៊្វុនស៊ិនប៉ិចនូវតំណែងមួយចំនួនក្នុងរដ្ឋាភិបាលអាណត្តិទី៤ ដែលគេនឹងបង្កើតនៅពេលខាងមុខនេះ។

តំណែងទាំងនោះរួមមានតំណែងឧបនាយករដ្ឋមន្ត្រី១រូបត្រូវបានទៅលើលោក *ញឹក ប៊ុនឆៃ* និងទេសរដ្ឋមន្ត្រីចំនួន៥រូប។ ប៉ុន្តែតំណែងទាំងនេះគឺសុទ្ធតែជាតំណែងខ្យល់ទាំងអស់ គ្មានអំណាចអ្វីដែលគួរឱ្យកត់សម្គាល់នោះទេ។

ទោះជាដូច្នេះក៏ដោយ ក៏មុខតំណែងដទៃទៀតដូចជា រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅតាមក្រសួងនានា ក៏មិនប្រាកដថា បានមកលើមន្ត្រីហ៊្វុនស៊ិនប៉ិចស្របតាមការរំពឹងទុកដែរ។ ព្រោះសូម្បីតែមន្ត្រីហ៊្វុនស៊ិនប៉ិចដែលធ្វើជាឯកអគ្គរាជទូតប្រចាំនៅបណ្តាប្រទេសចំនួន៧ត្រូវគណបក្សកាន់អំណាចមិនទុកឱ្យសល់ដង្ហើមដែរ ដែលស្មើនឹងមានន័យថា ហ៊្វុនស៊ិនប៉ិចក្នុងអាណត្តិទី៤នេះ "*ទូង១ដូចស្គរប្រហោងក្នុង*" តែម្តង។

យោងតាមវិបសាយរបស់ក្រសួងការបរទេសខ្មែរបានបង្ហាញថា ប្រទេសកម្ពុជាមានស្ថានទូត និងស្ថានកុងស៊ុលនៅក្នុងប្រទេសចំនួន២៤លើពិភពលោក ដែលភាគច្រើននៃមុខតំណែងឯកអគ្គរាជទូតកម្ពុជានេះ គឺមកពីគណបក្សប្រជាជនដែលកំពុងកាន់អំណាច។

ក្រុមអ្នកវិភាគនានាបានលើកឡើងថា ការដែលគណបក្សប្រជាជនកម្ពុជាស្រវ៉ារយកគណបក្សហ៊្វុនស៊ិនប៉ិចមានតែ២អាសនៈទៅធ្វើជាដៃគូចម្រុះក្នុងរដ្ឋាភិបាលនោះ គឺគ្រាន់តែជាលេសមួយដើម្បីការពារខ្លួនកុំឱ្យមានការចោទប្រកាន់ថា រដ្ឋាភិបាលអាណត្តិទី៤ខាងមុខនេះ ជារដ្ឋាភិបាលឯកបក្សអាចធ្លាក់ទៅក្នុងគន្លងផ្តាច់ការប៉ុណ្ណោះ។

ប៉ុន្តែប្រសិនបើមន្ត្រីហ៊្វុនស៊ិនប៉ិចដែលបានបញ្ចូលទៅក្នុងរដ្ឋាភិបាលចម្រុះនោះហើយ តែគ្មានអំណាចអ្វីសោះ ក៏នៅតែគេចមិនផុតពីការថ្កោលទោសថា រដ្ឋាភិបាលនេះជារដ្ឋាភិបាលឯកបក្សផ្តាច់ការដែរ។

គេបានវាយតម្លៃថា គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដោយអំពើលួចបន្លំ គឺឈ្នះទាំងព្រលឹងចុងសក់ ព្រោះរហូតមកដល់ពេលនេះទៅហើយអ្នកឈ្នះឆ្នោតទាំង៩០ជើងម៉ានៅតែសើចសេះទាំងមិនសូវសមនៅឡើយទេ។

ម្យ៉ាងទៀតនៅពេលដែលមានការផ្លាស់ប្តូរឯកអគ្គរាជទូតមកពីគណបក្សហ៊្វុនស៊ិនប៉ិចជំនួសដោយមន្ត្រីគណបក្សប្រជាជននោះ គឺពិតជាបង្ហាញឱ្យពិភពលោកឃើញថា កម្ពុជាមិនមែនជាប្រទេសប្រកាន់យកនូវរបបប្រជាធិបតេយ្យសេរីពហុបក្សទៀតទេ៕

### តមកពីទំព័រ១ ខ

ឈ្នះ ឬចាញ់ គ្មានការឈ្លោះគ្នាប្តីប្រពន្ធនៅកន្លែងបនល្បែងនោះទេ ។ ប៉ុន្តែមានបនល្បែងខ្លះដែលបើកលេងលួចលាក់នៅតាមផ្ទះ មានអ្នកញៀនល្បែងទៅលេង រាប់រយនាក់ដែរនោះជាបនល្បែងអត់ច្បាប់ និងអ្នកលេងខ្លះ បានឈ្លោះទាស់ទែងគ្នាប្តីប្រពន្ធ សឹងតែបង្កើតឱ្យមានអំពើហិង្សា នៅពេលអ្នកលេងចាញ់ធ្ងន់ធ្ងរនោះ ។

ក្រៅពីបនល្បែង សព្វសារពើ មានទាំងភ្ញៀវជាតិ អន្តរជាតិ ទាំងអ្នកមាន អ្នកក្រ ឬឧកញ៉ាមហាសេដ្ឋីនោះ ទីក្រុងភ្នំពេញសព្វថ្ងៃ ក៏ជាស្ថានសួគ៌របស់ក្មេងអន្ធពាលប្រណាំងរថយន្ត បង្ហោះម៉ូតូ និងប្រើប្រាស់ថ្នាំញៀន យ៉ាងពេញបន្ទុកដែរ គឺមានពេលខ្លះ ជាកូនអ្នកធំ ឬកូនក្មួយ លោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* តែម្តង ដែលភ្លើតភ្លើននឹងទ្រព្យសម្បត្តិ ប្រណាំងរថយន្ត គ្រោះថ្នាក់គ្រោះចរាចរ បណ្តាលអោយជនស្លូតត្រង់ស្លាប់យ៉ាងអយុត្តិធម៌ ។

បនល្បែងស៊ីសង ដែលមានច្រើនប្រភេទ នៅក្នុងទីក្រុងភ្នំពេញសព្វថ្ងៃនេះ វាបានបង្កើតឱ្យមានអសន្តិសុខសង្គមយ៉ាងខ្លាំង ដែលបញ្ហានេះកុំថាប្រជាពលរដ្ឋជាអ្នកដឹងនោះសូម្បីតែអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក៏បានដឹងយ៉ាងច្បាស់ដែរ ។ ប៉ុន្តែអ្នកប្រព្រឹត្តដែលជាម្ចាស់បនល្បែងបានសែនព្រេនប្រចាំថ្ងៃ ដល់សមត្ថកិច្ចមូលដ្ឋាន និងថៅកែល្បែងខ្លះ មានភាគហ៊ុនជាអ្នកមានអំណាចនោះបានធ្វើអោយជនសង្គមងងឹត បន្តអាជីវកម្មដែលពោរពេញ ដោយភាពអាក្រក់នៅក្នុងសង្គមកើតមានជារៀងរាល់ថ្ងៃគឺទាំងថ្ងៃទាំងយប់ ពិសេសបនល្បែងមួយ នៅផ្ទះល្វែង ក្បែរសាលាសង្កាត់ផ្សារដើមគរ ។

ពាក់ព័ន្ធ នឹងបនល្បែងនេះ *ខ្មែរម្ចាស់ស្រុក* ក៏ធ្លាប់បានចុះផ្សាយម្តងហើយ តាមសំណូមពរមិត្តអ្នកអាន ជាពិសេសក្នុងគោលបំណងឱ្យសមត្ថកិច្ចមានវិធានការជាបន្ទាន់ ។ ប៉ុន្តែតាំងពីការចុះផ្សាយពេលនោះ មកដល់ពេលនេះ ហាក់ដូចជាគេមិនឃើញមានសមត្ថកិច្ច មានវិធានការទៅលើបនល្បែងខុសច្បាប់នោះទេ, ផ្ទុយទៅវិញការចុះផ្សាយ របស់សារព័ត៌មានយើង ប្រែក្លាយជាទីផ្សាររបស់សមត្ថកិច្ចក្នុងការជំរិតទារលុយពីបនល្បែងកាន់តែច្រើនលើសដើម គឺមិនខ្វល់នឹងការនិន្ទារិះគន់ពីគ្រប់មជ្ឈដ្ឋានឡើយ ។

សេចក្តីរាយការណ៍មួយបានឱ្យដឹងថា មានបនល្បែងស៊ីសងដ៏ធំមួយកន្លែងនៅក្បែរសាលាសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ បនល្បែងដ៏ធំនេះ មានការការពារពីអ្នកមានអំណាចនិងបានបើកលេងទាំងយប់ទាំងថ្ងៃបណ្តាលអោយប្រជាពលរដ្ឋ ដែលមានលំនៅឋានក្បែរនោះ មានការក្តៅក្រហាយយ៉ាងខ្លាំង ។

អ្នកផ្សារដើមគរម្នាក់ បានប្រាប់ *ខ្មែរម្ចាស់ស្រុក* កាលពីថ្មីៗនេះថាបនល្បែងស៊ីសងខុសច្បាប់មួយកន្លែងដែលមានទីតាំងនៅផ្ទះលេខ៧ ផ្លូវលេខ ៣៣៦ នៅបញ្ចិតនឹងសាលាសង្កាត់ផ្សារដើមគរ កំពុងបើកលេងទាំងយប់ទាំងថ្ងៃ ។ប្រភពបានបន្តទៀតថាផ្ទះនោះ ជួលពីប៉ូលិសម្នាក់ឈ្មោះ*ឡើន* ដែលគេសង្ស័យថាមានភាគហ៊ុនបើកបនល្បែងខុសច្បាប់នេះ ។

ប្រជាពលរដ្ឋ បាននិយាយថា លោក*គង់ សុផាន់* ដែលជាចៅសង្កាត់ និងសមត្ថកិច្ចប៉េអឹម ប៉ូលិស នៅក្នុងសង្កាត់និងខណ្ឌនោះ ក៏បានដឹងអំពីសកម្មភាពខុសច្បាប់របស់ បនល្បែងនៅផ្ទះខាងលើនេះដែរប៉ុន្តែមិនហ៊ានចាត់ការទេ ពីព្រោះអ្នកដែលបើកបនល្បែងនេះ អាងអ្នកមានអំណាច ហើយពួកគេក៏បានសើមមាត់ជាមួយនឹងបនល្បែងនេះថែមទៀតផង ។

សេចក្តីរាយការណ៍ បានឱ្យដឹងថា កាលពីខែមុន មានស្រ្តីយួនម្នាក់ចាញ់ល្បែង នៅបនកន្លែងបនល្បែងស៊ីសងនេះ ធ្វើឱ្យប្តីមករករឿង ដល់កន្លែងលេង ឈ្លោះប្រកែកគ្នា ផ្អើលអ្នកលក់ដូរនៅក្បែរនោះ ។

ប្រជាពលរដ្ឋ ដែលមានលំនៅឋានក្បែរនោះ បានអោយដឹងថា ផ្ទះបនល្បែងនោះម្ចាស់ផ្ទះបានជួលឱ្យគេលក់បន្លែ នៅពីមុខ លើចំណីផ្លូវលេខ៣៣៦, ឯអ្នកលេងល្បែងខ្លះ ចូលតាមទ្វារខាងមុខ និងភាគច្រើន គេចូលតាមផ្លូវ ខាងក្រោយផ្ទះ។

អ្នកមានលំនៅឋាននៅក្បែរនោះបានស្នើសមត្ថកិច្ច សង្កាត់ ខណ្ឌ និងក្រុង មានវិធានការទៅលើផ្ទះបនល្បែងនេះ ជាបន្ទាន់ ដែលបង្កការភ័យខ្លាចជាពិសេស បារម្ភខ្លាចមានហេតុការណ៍អាក្រក់ណាមួយ ដែលប្តីប្រពន្ធឈ្លោះគ្នា បណ្តាលមកពីចាញ់ល្បែងនោះ ។

គួរបញ្ជាក់ថា បនល្បែងនៅស្រុកខ្មែរ មានជាច្រើនប្រភេទណាស់ គឺក្រុមហ៊ុនភ្នាល់បាល់ទាត់ ឆ្នោត កាស៊ីណូ ក្លឹបកំសាន្តតែបនល្បែងទាំងនេះសុទ្ធតែមានច្បាប់ប៉ុន្តែបនល្បែងនៅតាមផ្ទះ ដូចជាបនល្បែងនៅក្បែរសាលាសង្កាត់ ផ្សារដើមគរនេះជាដើមជាបនល្បែងខុសច្បាប់ ។

បនល្បែងស៊ីសង គ្រប់ប្រភេទនៅកម្ពុជាសព្វថ្ងៃបណ្តាលអោយមានចោរកម្មដូចជាចោរ ចោរឆក់ ចោរលួច ចោរគាស់ផ្ទះ និងចោរហារយជាច្រើនប្រភេទទៀត ។ ប៉ុន្តែសមត្ថកិច្ចមិនខ្វល់ អំពីការលំបាក របស់ប្រជាពលរដ្ឋទេ ហើយពួកគេគិតតែ ទទួលសំណូក ពីមេបនល្បែង បង្កឱ្យប្រជាពលរដ្ឋមានការភ័យខ្លាច អំពីសន្តិសុខនៅក្នុងសង្គមរាល់ថ្ងៃ ។

កាន់តែធ្ងន់ធ្ងរ ជាងនេះទៅទៀតនោះ ក្រុងភ្នំពេញសព្វថ្ងៃមិនមែនត្រឹមតែពោរពេញទៅដោយបនល្បែងស៊ីសងទេ គឺថែមទាំងសំបូរទៅដោយ ពួកក្មេងអន្ធពាល ជាកូនអ្នកធំកូនអ្នកមានប្រណាំងរថយន្ត និងបង្ហោះម៉ូតូក្នុងក្រុង ព្រមទាំងយុវជនប្រើប្រាស់គ្រឿងញៀនយ៉ាងពេញបន្ទុកទៀតផង ។ ទិដ្ឋភាពដ៏គួរឱ្យព្រឺខ្លាចនេះ គេមិនឃើញសមត្ថកិច្ច ពិសេសលោក*ទូច ណារុថ* ស្នងការនគរបាលក្រុងភ្នំនិងលោកអភិបាលក្រុង*កែប ជុតិមា* មានវិធានការយ៉ាងណាទេ ៕

### តមកពីទំព័រ១ គ

ប្រទេសកម្ពុជា ពិសេសតំបន់មាត់សមុទ្រ ក្រុងព្រះសីហនុ ដែលជាតំបន់ទេសចរណ៍ ធម្មជាតិដ៏ប្រណីតរបស់ខ្មែរ ។

លោក*ជេម ស្ប៊ន* ត្រូវគេស្គាល់ទូទាំងពិភពលោក និងផ្តល់រហស្សនាមថា ០០៧នោះ បានមកបំពេញទស្សនកិច្ច នៅកម្ពុជាជាលើកដំបូង ។

ដំណើរទស្សនកិច្ចដោយមិនបើកចំហនៅកម្ពុជា ជិត២០ថ្ងៃរបស់តារាភាពយន្តពិភពលោកនេះគឺលោក*ជេម ស្ប៊ន*បានជួបជាមួយស្ត្រីខ្មែរដ៏ឆ្នើមម្នាក់ គឺលោកស្រី*កុល សុខុម*រយៈពេល២សប្តាហ៍នៅទីក្រុងព្រះសីហនុដើម្បីស្វែងយល់ និងសិក្សាអំពីគំរោងអភិវឌ្ឍន៍នូវមជ្ឈមណ្ឌលធំៗតាមស្តង់ដារអន្តរជាតិ ។

លោកស្រី*កុល សុខុម* ដែលជាប្រធានក្រុមហ៊ុន LLK បានមានប្រសាសន៍ ប្រាប់*ខ្មែរម្ចាស់ស្រុក* កាលពីព្រឹកម្សិលមិញ ពាក់ព័ន្ធ នឹងដំណើរស្វែងយល់សិក្សាគំរោងអភិវឌ្ឍន៍ជាច្រើននៅក្រុងព្រះសីហនុនិងថាតារាភាពយន្ត ពិភពលោកមួយនេះ បានសរសើរមិនដាច់ពីមាត់ នូវធនធានធម្មជាតិរបស់ខ្មែរយើងដែលជាសម្បត្តិមហាសាល ។ លោកស្រីបានថ្លែងថា "*លោក ជេម ស្ប៊ន បានពណ៌នាថា ប្រទេសខ្មែរតូចមែនប៉ុន្តែសំបូរទៅដោយសម្បត្តិធម្មជាតិ ស្រស់បំព្រង ហើយគាត់ចង់និយាយអំពីខ្មែរ គាត់នឹងព្យាយាមជួយខ្មែរគឺគាត់ចាប់អារម្មណ៍អំពីប្រទេសខ្មែរយើងខ្លាំងណាស់ ។គាត់និយាយប្រាប់ខ្ញុំថា នេះជាលើកទីមួយហើយ ដែលគាត់បានស្គាល់ប្រទេសខ្មែរ, ហើយគាត់នឹកស្មានមិនដល់ទេ, គាត់បាននិយាយថា សូមខ្មែរកុំគិតថាខ្មែរខ្លួនឯងអន់ ខ្លួនឯងជាគ្រាប់ពេជ្រមួយ ដែលមិនទាន់មានអ្នកចេះកែច្នៃប៉ុណ្ណោះ*" ។

ដោយសារតែ បានស្តាប់នូវការកោតសរសើរ របស់តារាភាពយន្តហូលីវូដ ជនជាតិអង់គ្លេសដោយផ្ទាល់មាត់បែបនេះ លោកស្រី *កុល សុខុម* បានអំពាវនាវដល់ស្ត្រីខ្មែរគ្រប់រូបត្រូវតែរឹងប៉ឹង ក្លាហាន តាំងចិត្តជាស្ត្រីដ៏ល្អ ដល់ស្ត្រីគ្រប់រូប ក្នុងការរៀបចំខ្សែជីវិត អោយល្អប្រសើរ ។ លោកស្រីបានមានប្រសាសន៍ថា "*យើងជាស្ត្រីត្រូវធ្វើយ៉ាងណា ព្យាយាមធ្វើ ខ្លួនឱ្យបានល្អ ទាំងគំនិត និងទាំងបញ្ញា ដើម្បីទាក់ទាញដល់អ្នកវិនិយោគទុនពិភពលោក គេមកដាក់ទុនរកស៊ីនៅកម្ពុជា ។ ខ្ញុំសូមឱ្យស្ត្រីខ្មែរ បង្កើននូវចំណេះដឹង ដើម្បីឱ្យពិភពលោកមានការចាប់អារម្មណ៍, ហើយចំណែកខ្លួនខ្ញុំៗនឹងព្យាយាមជាបន្តទៀត ។ អ្វីគ្រប់យ៉ាង ខ្ញុំខំព្យាយាមគ្រប់យ៉ាង ដើម្បីប្រទេសជាតិយើង និងប្រជាពលរដ្ឋយើង សូម្បីត្រូវពលីអ្វីគ្រប់យ៉ាងក៏ខ្ញុំលះបង់ ដើម្បីកូនខ្មែរដែរ ។ ខ្ញុំចង់ធ្វើជាគំរូដល់ស្ត្រីខ្មែរ ដើម្បីឱ្យល្អ ធ្វើឱ្យកក្រើកដល់ពិភពលោក ទាំងការងារវិនិយោគ...*" ។

លោកស្រី បានបន្តទៀតថា លោក*ជេម ស្ប៊ន* បានបញ្ជាក់ថា គាត់នឹងមកបំពេញទស្សនកិច្ចនៅកម្ពុជាជាបន្តទៀត ។ ចំពោះដំណើរទស្សនកិច្ច នៅទីក្រុងព្រះសីហនុ រយៈពេល២សប្តាហ៍កន្លងទៅនេះលោក*ជេម ស្ប៊ន*បានរៀបចំអប្បកិរិយាជាខ្មែរ ដែលសូម្បីតែអាហារ ក៏គាត់ចូលចិត្តទទួលទានអាហារខ្មែរយើងដែរ ដូចជាសម្លម្ជូរជាដើម ។

លោកស្រី*កុល សុខុម* បានមានប្រសាសន៍ តាមសម្តីតារាភាពយន្ត*ជេម ស្ប៊ន* ទៀតថា ស្ត្រីខ្មែរស្អាត តូចច្រឡឹង ប៉ុន្តែទាបបន្តិច ។

លោក*ជេម ស្ប៊ន* បានចាកចេញ ពីអាណាចក្រកម្ពុជាវិញហើយ កាលពីថ្ងៃទី៤ កញ្ញា ២០០៨ដោយលោកបានសន្យាថានឹងមកកម្ពុជា នៅក្នុងពេលឆាប់ៗនេះ ដោយធ្វើវិនិយោគរួមគ្នា ជាមួយលោកស្រី*កុល សុខុម* ធ្វើឱ្យកក្រើក នៅតំបន់អាស៊ី ។ ជាមួយគ្នានោះដែរ លោក*ជេម ស្ប៊ន* ក៏បានថ្លែងថា នឹងចងក្រងនូវឯកសារល្អៗ អ្វីដែលលោក បានមកឃើញអំពីភាពពិតនៅកម្ពុជា អោយទស្សនាវដ្តីពិភពលោក ធ្វើការចុះផ្សាយផងដែរ ។ លោក*ជេម ស្ប៊ន* ក៏បានបង្ហើប អំពីទេសភាពធម្មជាតិនៅកម្ពុជា ធ្វើឱ្យលោក មានគំរោងមកថតភាពយន្តនាពេលអនាគតឆាប់ៗនេះផងដែរ ៕

### តមកពីទំព័រ២ ង

*រយចំពោះការផ្ទេរដីមហោស្រពក្រុងព្រះសីហនុមួយកន្លែងនេះ គឺមានចំនួនជិត៣០ម៉ឺនដុល្លារអាមេរិកឯណោះ ។ប៉ុន្តែគួរឱ្យសោកស្តាយណាស់ព្រោះប្រពន្ធលោក ស្បោង សារ៉ាត មិនដឹងជាអាងអំណាចប្តីឬអាងអំណាចអ្នកណានោះទេ ទើបបានជាមិនព្រមបង់ប្រាក់ពន្ធជូនរដ្ឋយ៉ាងដូច្នេះ* "។

ឥឡូវនេះប្រជាពលរដ្ឋនៅក្រុងព្រះសីហនុកំពុងយកដៃរីតទ្រូងដោយការហួសចិត្តស្ទើរគ្រប់គ្នានៅពេលដែលគេមើលឃើញថា ទីតាំងមហោស្រពថ្មីត្រូវបានគេយកទៅដាក់នៅកណ្តាលព្រៃ (ដូរពីកណ្តាលក្រុង) សំបូរទៅដោយសត្វពស់មានពិសស្អេកស្កះពេញដី។

មិនតែប៉ុណ្ណោះសូម្បីតែការសាងសង់សំណង់មហោស្រពថ្មីក៏យឺតយ៉ាវសម្បើមណាស់ដែរ ដែលធ្វើឱ្យមន្ត្រីរាជការបុគ្គលិកនៃមន្ទីរវប្បធម៌វិចិត្រសិល្បៈក្រុងព្រះសីហនុធ្លាក់ខ្លួនវេទនាព្រោះគ្មានកន្លែងធ្វើការក៏នាំគ្នាដេកស៊ីប្រាក់ខែនៅតាមផ្ទះរៀងៗខ្លួនអញ្ចឹងទៅ។

នៅមានទីតាំងមន្ទីរសាធារណការនិងដឹកជញ្ជូនក្រុងព្រះសីហនុមួយកន្លែងទៀតដែលស្ថិតនៅតាមបណ្តោយវិថីឯករាជ្យក្នុងភូមិសាស្ត្រសង្កាត់២ ខណ្ឌមិត្តភាពក្រុងព្រះសីហនុ ដែលមានទំហំប្រមាណជាង៣ហិកតា ក៏បានធ្លាក់ទៅក្នុងកណ្តាប់ដៃឈ្មួញតាមរយៈប្រពន្ធលោក *ស្បោង សារ៉ាត* រត់ការដែរ។ ហើយពេលនេះត្រូវបាន និងកំពុងរើទីតាំងទៅក្នុងគន្លកថ្មមួយកន្លែងនៅសង្កាត់១ ខណ្ឌមិត្តភាពទៅវិញដែលមើលទៅឃើញគួរឱ្យវេទនាក្រៃកសម្បើមណាស់។

ក្នុងនោះបើនិយាយអំពីតម្លៃនៃទីតាំងមន្ទីរសាធារណការនិងដឹកជញ្ជូនក្រុងព្រះសីហនុវិញក៏ខ្ទង់លានដុល្លារអាមេរិកដែរ។ នេះបើតាមហាងឆេងដីធ្លីនៅក្រុងព្រះសីហនុបច្ចុប្បន្ន។

ប្រភពផ្តល់ព័ត៌មានបានឱ្យដឹងទៀតថា ទីតាំងមន្ទីរសង្គមកិច្ច និងយុវនីតិសម្បទាក្រុងព្រះសីហនុដែលនៅជិតរង្វង់មូលតោពីរ ក៏ត្រូវរត់ការលក់បាត់ស្រមោលដែរ។ ហើយបើចង់ទំនាក់ទំនងមន្ទីរសង្គមកិច្ចនេះ គឺនៅជិតវត្តឥន្ទញាណហៅវត្តក្រោមឯណោះ។

ម្យ៉ាងទៀតទីតាំងកីឡដ្ឋានក្រុមមឿងដែលជាទ្រព្យសម្បត្តិដ៏មហាសាលរបស់មន្ទីរអប់រំយុវជននិងកីឡាក្រុងព្រះសីហនុមានទំហំប្រមាណជាង៥ហិកតានៅជិតឆ្នេរអូរតែល៧ជាន់ក៏ត្រូវបានគេរត់ការពីក្រោមទៅលើ, ពីលើមកក្រោមលក់បាត់អស់ទៅហើយ ។នៅពេលដែលមានការសួរនាំទៅ គឺសុទ្ធតែគ្មានអ្នកទទួលខុសត្រូវសោះ ព្រោះថ្នាក់ក្រោមរុញទៅថ្នាក់លើ ឯថ្នាក់លើទម្លាក់មកថ្នាក់ក្រោមជាបន្តបន្ទាប់។

ទាក់ទិននឹងប្រពន្ធលោក *ស្បោង សារ៉ាត* មេគណបក្សប្រជាជនក្រុងព្រះសីហនុពូកែរត់ការលក់អចលនទ្រព្យរបស់រដ្ឋនេះដែរ មានគេបង្ហើបឱ្យយើងដឹងទៀតថា មាត់សមុទ្រអូរតែល៧ជាន់ដែលមានបណ្តោយឆ្នេរប្រមាណ២០០០ម៉ែត្រ ក៏ត្រូវបានប្រពន្ធលោក *ស្បោង សារ៉ាត* យើងរត់ការលក់ទៅឱ្យក្រុមហ៊ុនមួយ។ ហើយពេលនេះគេបានហ៊ុំព័ទ្ធដោយស័ង្កសីជិតមិនឱ្យប្រជាពលរដ្ឋ ឬភ្ញៀវទេសចរចូលទៅកំសាន្តនៅឆ្នេរសមុទ្រនោះបានឡើយ។

នៅមានដីព្រៃតំបន់ក្បាលឆាយមួយកន្លែងទៀត ក៏ត្រូវប្រពន្ធលោកមេបក្សប្រជាជនក្រុងព្រះសីហនុរត់ការកាត់ចេញពីអនុក្រឹត្យក្បាលឆាយ យកមកធ្វើជាកម្មសិទ្ធិផ្ទាល់បានរាប់សិបហិកតាដែរ។ គិតទៅប្រពន្ធលោក *ស្បោង សារ៉ាត* ពិតជាពូកែរកលេខដាក់គ្មានមែន។

អញ្ចឹងទេនៅពេលដែលលោក *ស្បោង សារ៉ាត* ឡើងធ្វើជាចៅហ្វាយធំនៅក្រុងព្រះសីហនុហើយ គឺប្រពន្ធលោក *ស្បោង សារ៉ាត* នឹងប្រមូលលក់ខ្ទេចគ្មានសល់អ្វីឡើយ ដែលសូម្បីតែមន្ត្រីគណបក្សប្រជាជនខ្លះក៏មិនគាំទ្រនឹងទង្វើរបស់ក្រុមគ្រួសារលោក *ស្បោង សារ៉ាត* ផង។

គេជឿថា អាណត្តិក្រោយគណបក្សប្រជាជននឹងបរាជ័យនៅក្រុងព្រះសីហនុក្រោមស្នាដៃលោក *ស្បោង សារ៉ាត* ជាមិនខាន៕

### តមកពីទំព័រ៤ ស

ទៅជាប្រទេសផ្តាច់ការវិញ ។ លោកបានថ្លែងថា "*ការយកអាសនៈ របស់គណបក្សសមរង្ស៊ីទៅចែកគ្នា ឬយកដោយផ្ទាល់ខ្លួនឯងនោះ វានឹងបង្កើតអោយទៅជាមានវិបត្តិដ៏ធំមួយ ហើយកម្ពុជា នឹងក្លាយទៅជាប្រទេសផ្តាច់ការមួយរំពេច ពីព្រោះយើងឃើញហើយ របបផ្តាច់ការ គឺបក្ស និងរដ្ឋគេគ្រប់គ្រងទាំងអស់ ដូចគណបក្សប្រជាជនធ្លាប់ធ្វើរឿងហ្នឹងរួចទៅហើយ ក្នុងសម័យរដ្ឋកម្ពុជា គឺរដ្ឋ និងបក្សតែមួយ, ហើយរដ្ឋនិងបក្សហ្នឹង ក៏ជារដ្ឋាភិបាលដូចគ្នា សភាក៏របស់បក្ស តុលាការជារបស់បក្ស ប៉ូលិសរបស់បក្ស ទាហានរបស់បក្ស ដីធ្លីរបស់បក្សទាំងអស់ ចង់អោយទៅនរណាក៏ឱ្យទៅ ចង់ឈានទៅរករបបចាស់មួយ ដែលជារបបធ្វើអោយយើងមានបញ្ហាជម្លោះរវាងជាតិឯង ។ រឿងនេះយើងមិនត្រូវបំភ្លេចទេ គឺយើងត្រូវតែ ចោះត្រចៀកចាំ ដោយសារ របបផ្តាច់ការនេះហើយ ដែលធ្វើឱ្យយើងមានជំលោះរ៉ាំរ៉ៃ ធ្វើឱ្យជាតិយើងរងទុក្ខវេទនា ធ្វើអោយប្រទេសជិតខាងគេមើលងាយគេឈ្លានពានទឹកដីរបស់យើង, ហើយវិលទៅរបប ដដែលហ្នឹងទៀត បំភ្លេចចោល កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលយើងបានសំរេចរួមគ្នាថា យើងបោះបង់ចោល របបផ្តាច់ការ ហើយត្រូវតែ ទទួលស្គាល់សិទ្ធិនយោបាយរបស់ពលរដ្ឋហើយបង្កើតរបបគ្រប់គ្រងមួយដើម្បីផ្សះផ្សាជាតិ តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស*" ។

លោក*សុន ឆ័យ* បានសំដែងនូវភាពសោកស្តាយ បន្ទាប់ពីឮសម្តីលោក*ខៀវ កាញារីទ្ធ* ថា សមាជិកាសភា គណបក្សសមរង្ស៊ីទាំង២៦រូប នឹងក្លាយទៅជាគ្មានន័យនោះ ។ លោកបានថ្លែងថា "*ខ្ញុំសោកស្តាយនៅពេលឮសម្តី លោកខៀវ កាញារីទ្ធ មានប្រសាសន៍បែបនេះ ព្រោះលោកខៀវ កាញារីទ្ធ ក៏ជាមន្ត្រីជើងចាស់មួយរូប ហើយក៏ជាបញ្ញវន្ត ដែលអាចយល់បានច្រើន នូវអ្វីដែលជាលទ្ធិប្រជាធិបតេយ្យសេរី ។ យើងគួរតែនាំគ្នាពិនិត្យមើល ថាតើគួរធ្វើដូចម្តេច ដើម្បីធ្វើការកែលំអ ទៅលើការគ្រប់គ្រងស្ថាប័នយើង ធ្វើការបំរើរាស្ត្រម្តងទៅ កុំយកតួនាទីរដ្ឋ ទៅជិះជាន់ធ្វើបាបប្រជារាស្ត្រឯង*" ។

លោក*សុន ឆ័យ* បានបន្តថា មានសមាជិកសភា គណបក្សប្រជាជនខ្លះ មិនហ៊ាននិយាយការពិតទេ នាពេលកន្លងមកគឺពឹងឱ្យលោកលើកឡើង ពាក់ព័ន្ធ ទៅនឹងក្រុមហ៊ុនរោងចក្រខ្លះ ដែលបានធ្វើឱ្យខូចបរិស្ថាននៅក្នុងទីក្រុងភ្នំពេញ ដែលប៉ះពាល់ដល់សុខភាព ប្រជាពលរដ្ឋជាដើម ។

ដូច្នេះហើយ បានជាលោក*សុន ឆ័យ* សំដែងការហួសចិត្តនឹងលោក*ខៀវ កាញារីទ្ធ* ថា មិនស័ក្តិសម ជាអ្នកចេះដឹងទេ ដែលហ៊ាននិយាយថាសមាជិកសភាគណបក្សសម រង្ស៊ី ទាំង២៦រូបនឹងក្លាយជាគ្មានន័យបើសិនជា មិនព្រមចូលស្បថ ជាមួយពួកគេ តាមគំរោងនៅថ្ងៃទី២៤ កញ្ញា ២០០៨ទេនោះ ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា
-មានទទួលទិញក្នុងតម្លៃសមរម្យ
-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ជាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

Tel: 012 850 690 / 017 360 678 , Fax: 023 987 411

**តមកពីទំព័រ១ ម**

តាមទឹកដីព្រំដែនដែលកំពុងត្រួតត្រាកាន់កាប់ដោយព្រួកប្រដាប់អាវុធសៀម បំពានចូលយ៉ាងគឃ្លើននោះ។

ជុំវិញបញ្ហានេះបណ្ឌិតវិទ្យាសាស្ត្រនយោបាយម្នាក់ បាននិយាយថា ប្រសិនបើរកដំណោះស្រាយទ្វេភាគីដូចសព្វថ្ងៃនៅតែជាការលំបាកខ្លាំង ដោយសារសៀមមានចេតនាមិនចង់បានការចរចាដោះស្រាយដោយសុច្ចរិតទេនោះកម្ពុជាមានតែជម្រើសយករឿងនេះទៅតវ៉ានៅអង្គការសហប្រជាជាតិ។

បណ្ឌិត *រស់ ចន្ទ្រាបុត្រ* នៃរាជបណ្ឌិតសភាកម្ពុជាបាននិយាយថា "*បើដោះស្រាយជាការចរចាទ្វេភាគីលំបាកឆ្លងដល់អន្តរជាតិ ដល់សហប្រធានទាំងពីរនៃកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១នោះ បើមិនមានដំណោះស្រាយចេញរួចទេ មានតែយករឿងនេះទៅប្តឹងដល់អង្គការសហប្រជាជាតិ* "។

សៀមដូចជាបង្ហាញឱ្យឃើញកាន់តែច្បាស់ និងដោយគំនិតទុច្ចរិតរបស់ខ្លួនយ៉ាងស្ដែង អំពីការដែលខ្លួនពុំមានចេតនាចង់ឱ្យមានការដោះស្រាយដោយសន្តិវិធី តាមវិធីចរចាផ្នែកការទូត ក្នុងគោលដៅបញ្ចប់ការប្រឈមមុខអាវុធដាក់គ្នារវាងកងទាហានសៀមឈ្លានពាន និងទាហានខ្មែរនៅតំបន់ជាយដែននៃប្រទេសទាំងពីរនោះឡើយ។

រឿងនេះបណ្ឌិត *រស់ ចន្ទ្រាបុត្រ* បាននិយាយថា សៀមដូចជាព្យាយាមដាក់នយោបាយចង់ឱ្យមានការពន្យារពេលនៃកិច្ចចរចា។ លោកបាននិយាយទៀតថាទាហានសៀមមិនស្តាប់រដ្ឋាភិបាលរបស់គេទេ បើដូច្នេះតើកម្ពុជាទៅចរចាជាមួយនរណា?

តាមការមើលឃើញ និងតាមដានការវិវឌ្ឍន៍នៃស្ថានការណ៍នេះក៏ដូចជាប្រវត្តិសាស្ត្ររបស់កម្ពុជាជាហូរហែមកនោះ លោកបណ្ឌិតបានអធិប្បាយថា សៀមព្យាយាមអូសបន្លាយពេលវេលាដូចជាប្រាថ្នាចង់បានចំណេញលើការកាន់កាប់ទឹកដីខ្មែរ។លោកបានប្រើពាក្យយ៉ាងនេះថា "*សៀមអត់មានអីខាតទេ។ វាមានតែចំណេញ ឬក៏រួចខ្លួន* "។

ជាបន្ថែមនោះ អ្នកសង្កេតការណ៍រូបនេះក៏បានកត់សម្គាល់នូវការដែលពួកអ្នកនយោបាយសៀម ពិតមែនតែគេឈ្លោះគ្នាក៏គេចេះរួមគ្នា ដែលធ្វើឱ្យប្រទេសជាតិគេចំណេញនៅត្រង់ថា ទាហានរបស់គេចេះតែបន្តចូលកាន់កាប់ទឹកដីខ្មែរតាមតំបន់ព្រំដែន ជាលេសដើម្បីចង់បានដីខ្មែរអស់ទាំងនោះក្នុងស្ថានភាពដែលប្រទេសគេមានចលាចលនយោបាយរីករវក៏ដោយ។

ច្រកផ្លូវតែមួយគត់ដែលកម្ពុជាសង្ឃឹមមួយរយភាគរយលើភាពឈ្នះតាមផ្លូវច្បាប់ដោយកិត្តិយសពេញមុខ និងសេចក្តីថ្លៃថ្នូរ ទាំងជាវិធីអហិង្សាទទួលស្គាល់ដោយសហគមន៍អន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិក្នុងបំណងបញ្ចប់បញ្ហារំលោភចូលដីខ្មែរដោយប្រទេសជិតខាងនោះ ត្រូវបានបណ្ឌិត *រស់ ចន្ទ្រាបុត្រ* ថ្លែងថា មានតែការងាកទៅប្តឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប៉ុណ្ណោះ។

លោកបាននិយាយថា "*ត្រូវឱ្យអង្គការសហប្រជាជាតិ ឬក៏យកកម្លាំងអន្តរជាតិមកដាក់ទប់កុំឱ្យកងទ័ពសៀមចេះតែរំកិលចូលមកទៀត* "។

ឥឡូវនេះនៅក្រោយពីមានការជួបចរចាគ្នាច្រើនលើកច្រើនសារដូចជានៅអារញ្ញប្រថេតកាលពីថ្ងៃទី២១ ខែកក្កដា ការចរចាមួយលើកទៀតថ្នាក់រដ្ឋមន្ត្រីការបរទេសខ្មែរ *ហោ ណាំហុង* និងសៀម *តេជ ប៊ុនណាក* នៅខេត្តសៀមរាប ថ្ងៃទី២៨ ខែកក្កដា រហូតដល់ការជួបចរចាគ្នាថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសនៅហួរហ៊ិន ទឹកដីសៀម ថ្ងៃទី១៨-១៩ ខែសីហា មកដល់ពេលនេះ ស្ថានការណ៍នៅតាមតំបន់ព្រំដែននៅតែពុំមានភាពធូរស្រាលឡើយ។

ហើយឥឡូវនេះទៀត រដ្ឋមន្ត្រីការបរទេសរបស់សៀម *តេជ ប៊ុនណាក់* ទើបតែបានប្រកាសលាលែងចេញពីតំណែងរបស់ខ្លួន។ រឿងនេះកាន់តែធ្វើឱ្យស្ថានការណ៍នៃចំហរនយោបាយរបស់រដ្ឋាភិបាលកម្ពុជា *ហ៊ុន សែន* ជាប់ផុងលង់ខ្លួនជ្រៅទៅៗក្នុងអន្ទាក់ល្បិចការទូតរបស់សៀម។

គេមិនដឹងថា តើសៀមនឹងអនុវត្តផែនការនយោបាយអ្វីទៀតនោះទេ ប្រសិនបើមានការជ្រើសរើសរដ្ឋមន្ត្រីការបរទេសថ្មីមកជំនួសនោះ បើសូម្បីតែពេលនេះ នាយករដ្ឋមន្ត្រីសៀម *សាម៉ាក់ ស៊ុនដារ៉ាវេត* ក៏កំពុងប្រឈមនឹងគំនាបនយោបាយឱ្យលាលែងចេញពីតំណែងនោះ។

បើទោះបីជាសៀមជាពិសេសទាហានសៀមដែលបានចូលកាន់កាប់ទឹកដីមាត់ហាវនិយាយថារង់ចាំបញ្ជាពីលើមកក៏ដោយ ក៏ពួកទាហានសៀម ដូចជាបានទទួលបញ្ជាពីមេកោយរបស់ខ្លួនឱ្យរុលចូលកាន់កាប់ទឹកដីខ្មែរដូចឃើញមានបច្ចុប្បន្ននេះទៀត។ មិនមែនតែនៅវត្តកែវសិក្ខាគីរីស្វារៈឬប្រាសាទតាមាន់នោះទេដែលទឹកដីខ្មែរត្រូវទាហានសៀមចូលមករំលោភកាន់កាប់។ នៅតំបន់ដទៃទៀតដូចជាច្រកជាំសាង៉ុំ ច្រកជប់ក្រឡ ក៏ត្រូវពួកទាហានសៀមចូលមកអុកឡុកដែរ។ ពួកទាហានសៀមអស់ទាំងនេះថែមទាំងបានចូលមកកាប់បំផ្លាញដំណាំរបស់កសិករខ្មែរនៅទីនោះទាំងគំរាមបណ្តេញខ្មែរឱ្យរុះរើផ្ទះសម្បែងថយចេញពីភូមិនៅជាប់ព្រំដែន ចូលមកជ្រៅក្នុងទឹកដីខ្មែរទៀត។

មន្ត្រីរដ្ឋាភិបាលកម្ពុជាជាពិសេសរដ្ឋមន្ត្រីការបរទេស *ហោ ណាំហុង* កាលពីថ្ងៃសុក្រសប្តាហ៍មុន បានទទួលការណែនាំពីនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ឱ្យស្វះស្វែងរកជួបចរចាជាមួយរដ្ឋមន្ត្រីការបរទេសសៀមអំពីការដែលទាហានសៀមបានលើកគ្នាចូលមកកាន់កាប់ទឹកដីខ្មែរ។ ប៉ុន្តែអ្វីដែលលោក *ហ៊ុន សែន*លើកជាចំណាត់ការក៏ត្រូវពួកអ្នកសង្កេតការណ៍មើលឃើញថាជាដំណើរយឺតតាមក្រោយសៀមមិនទាន់ ដូចជាឥឡូវរដ្ឋមន្ត្រីការបរទេសសៀម *តេជ ប៊ុនណាក* ក៏បានលាចេញពីតំណែងបាត់ទៅហើយ។

នេះហើយដែលប្រាប់ឱ្យដឹងថា នយោបាយការទូតដែលមិនយល់អំពីកាលៈទេសៈ នៃស្ថានការណ៍នៅនឹងកន្លែងជាក់ស្តែងក៏ដូចជាមិនយល់អំពីស្ថានភាពដោះស្រាយឱ្យសមនឹងទំហំបញ្ហានៅលើឆាកអន្តរជាតិនោះ ធ្វើឱ្យកម្ពុជាធ្លាក់ខ្លួនបន្តរងគ្រោះដូចឃើញបច្ចុប្បន្ននេះ។

មេដឹកនាំកម្ពុជាបានត្រឹមតែនិយាយទទួលស្គាល់ទាំងមិនហ៊ានហើបមាត់ព្រោះខ្មាស់អៀននឹងកំហុសនយោបាយរបស់ខ្លួនដែលចេះតែធ្វើតាមសៀម ម្តងសៀមទាមទារឱ្យដកទ័ពថយពីដីខ្មែរក៏ព្រម ម្តងសៀមទាមទារឱ្យដកបណ្តឹងពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ *ហ៊ុន សែន*ក៏ព្រមធ្វើតាមសៀមដែលនេះជាហូរហែរធ្វើឱ្យសៀមកាន់តែបានចិត្ត។ គេបានឮមន្ត្រីទទួលខុសត្រូវខាងចរចាបញ្ហាព្រំដែនខ្មែរ-សៀមនិយាយអំពីអនុសញ្ញាបារាំង-សៀមឆ្នាំ១៩០៤ ១៩០៧ដែលពេលនោះបារាំងក្នុងឋានៈជាអ្នកគ្រប់គ្រងកម្ពុជាបានចុះហត្ថលេខាជាមួយសៀមស្តីពីតំបន់ព្រំដែននៃប្រទេសទាំងពីរ ហើយនឹងសាលក្រមតុលាការអន្តរជាតិក្រុងឡាអេឆ្នាំ១៩៦២។

អស់ទាំងនេះជាឯកសារនិងតឹកតាងព្រមទាំងបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជានឹងឈ្នះយ៉ាងងាយលើសៀមនៅវេទិកាអន្តរជាតិដូចជាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បើមេដឹកនាំខ្មែរ ជាពិសេស *ហ៊ុន សែន* ចេះគិតជាតិជាធំនោះ៕

**តមកពីទំព័រ១ ស**

នេះផ្តើមចេញពីសមាជិកសភាគណបក្សសម រង្ស៊ី ចំនួន២៦រូប ដែលតំណាងឱ្យប្រជាពលរដ្ឋខ្មែរពិតប្រាកដ មិនព្រមចូលស្បថ ជាមួយអ្នកតំណាងរាស្ត្រគណបក្សប្រជាជនចំនួន៩០រូបដែលអ្នក បោះឆ្នោតអោយខ្លះលាយឡំដោយជនជាតិយួននិងឈ្មោះខ្មោច ។

សមាជិកសភាថ្មី របស់គណបក្សសម រង្ស៊ីទាំង២៦រូប បានសរសេរលិខិតទូលថ្វាយស្តេចព្រះព្រះមហាក្សត្រ ព្រះបរមនាថ *នរោត្តម សីហមុនី* ឱ្យពន្យារពេលនៃការចូលស្បថរបស់អ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ីនៅថ្ងៃទី២៥កញ្ញា ២០០៨ ដាច់ដោយឡែក ពីអ្នកតំណាងរាស្ត្រគណបក្សប្រជាជន ដែលគ្រោងធ្វើ នៅថ្ងៃទី២៤ កញ្ញា ២០០៨ ។ សំណើរបស់សមាជិកសភា គណបក្សសម រង្ស៊ី នេះ ត្រូវលោក*ខៀវ កាញារីទ្ធ* អះអាងថា នឹងធ្វើឱ្យសមាជិកសភា របស់គណបក្សសម រង្ស៊ី ទាំង២៦នោះ ក្លាយទៅជាគ្មានន័យ ។ ពាក្យសម្តីលោក*ខៀវ កាញារីទ្ធ* នេះ ត្រូវលោក*សុន ឆ័យ* អះអាងថា ជាសម្តី មិនស័ក្តិសមជាអ្នកចេះដឹងទេ ។

លោក*សុន ឆ័យ* បានប្រាប់ *ខ្មែរម្ចាស់ស្រុក*កាលពីថ្ងៃម្សិលមិញ នៅទីស្នាក់ការកណ្តាលគណបក្សសម រង្ស៊ីពាក់ព័ន្ធទៅនឹងអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ទាំង២៦រូប មិនចូលរួមសម្បថ នៅថ្ងៃទី២៤ កញ្ញា ឆ្នាំ២០០៨ថា "*ធម្មតាការស្បថស្បែដោយឡែកនេះ មិនមែនជាបញ្ហាទេ គឺយើងបានបញ្ជាក់ហើយបញ្ជាក់ទៀតថា យើងចូលស្បថដោយឡែកនេះគឺមកពីយើងមិនអស់ចិត្ត នូវអ្វីដែលជាភស្តុតាង បណ្តឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតី នៃការបោះឆ្នោត ដែលត្រូវស្ថាប័ន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក៏ដូចជាក្រុមប្រឹក្សាធម្មនុញ្ញបដិសេធ ធ្វើឱ្យប្រជាពលរដ្ឋមិនសុខចិត្ត* " ។

លោក*សុន ឆ័យ* បានបន្តថា ភាពជាក់ស្តែង នៃការក្លែងបន្លំសន្លឹកឆ្នោត ដែលទាំងអស់នេះ ប្រជាពលរដ្ឋ មិនសុខចិត្តទេ, ហើយគេ ចង់អោយមានការបង្ហាញជាសាធារណៈមួយដើម្បីកុំអោយអំពើទាំងនេះ ប្រព្រឹត្តទៅទៀត ។ លោកបានថ្លែងទៀតថា យើងគ្រាន់តែសំដែងនូវឆន្ទៈប្រជារាស្ត្រ ដើម្បីកុំឱ្យច្រឡូកច្រឡំគ្នាហើយបើសិនជាមានការបោះឆ្នោតឱ្យត្រឹមត្រូវនោះ ចំនួនអាសនៈរបស់គណបក្សប្រជាជន មិនបាន៩០ទេ, ដូច្នេះមិនអាចឱ្យយើង ជាអ្នកតំណាងរាស្ត្រ គណបក្ស សម រង្ស៊ីទៅចូលរួមស្បថជាមួយអ្នកដែលយើងមិនជឿថា ជាអ្នកតំណាងរាស្ត្រ ដែលគាំទ្រពីប្រជារាស្ត្រ គឺជាការលំបាកមួយ ។ ដូច្នេះហើយ បានជាសមាជិកសភាថ្មីរបស់គណបក្សសមរង្ស៊ីសុំឱ្យមានការស្បថដោយឡែកពី គណបក្សប្រជាជន ។

លោក*សុន ឆ័យ* បានមានប្រសាសន៍ថា "*នេះគឺជាគោលការណ៍លទ្ធិប្រជាធិបតេយ្យ គឺគេអាចធ្វើពហិការ គេអាចធ្វើការសំដែងប្រតិកម្ម តាមបែបបទផ្សេងៗ* " ។

ចំពោះសម្តី មន្ត្រីគណបក្សប្រជាជនព្រមានថានឹងយកកៅអីសភា របស់គណបក្សសម រង្ស៊ី ទាំង២៦ទៅចែកគ្នានោះ, លោក*សុន ឆ័យ* បានព្រមានថានឹងធ្វើឱ្យស្ថានការណ៍ នយោបាយនៅកម្ពុជា ធ្លាក់ដុនដាបយ៉ាងធ្ងន់ធ្ងរ ហើយនាំកម្ពុជាឱ្យ

**តទៅទំព័រ៣ ស**

**តមកពីទំព័រ១ ក**

**បាននិយាយប្រាប់វិទ្យុអាស៊ីសេរីផ្សាយកាលពីយប់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៨ជាថ្មីទៀតអំពីការដែលគេបានរកឃើញ និងរឹបអូសយកបានមាសមិនតិចជាង១២តោន និងពេជ្រជាង២គីឡូក្រាមពី ប៉ុល ពត ដែលបានរត់ទៅតំបន់ជាយដែនខាងលិចប្រទេស។**

**មាសទាំងជាង១ម៉ឺន២ពាន់គីឡូក្រាមដែលរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហម បានរឹបអូសជារបស់ជាតិផង ជារបស់ប្រជារាស្ត្រគ្រប់ទិសទី ជាពិសេសគឺអ្នកចេញពីទីក្រុង ពីទីប្រជុំជនយកទៅរំលាយចូលគ្នាអស់ទាំងនោះ គឺជាសម្បត្តិរបស់ប្រទេសជាតិ ហើយដែលការរឹបអូសយកនោះធ្វើឡើងនៅពេលកងទាហានយួន និងខ្មែរបានធ្វើការវាយរំលំរបបខ្មែរក្រហម។ ប៉ុន្តែមកដល់ពេលនេះគេមិនដឹងថា សម្បត្តិអស់ទាំងនេះរបស់ប្រទេសជាតិ និងរបស់ប្រជារាស្ត្រខ្មែរធ្លាក់ទៅក្នុងកណ្តាប់ដៃនរណា ឬមួយក៏ពួកទាហានយួនបានរំលែកយកទៅខ្លះ ឬក៏ពួកអ្នកកាន់អំណាចនៅកម្ពុជាបំភ្លៃកេងប្រវ័ញ្ចយកទៅចែកគ្នាជាសម្បត្តិរបស់ខ្លួនយ៉ាងណានោះឡើយ។**

**តាមការរៀបរាប់របស់លោក ប៉ែន សុវណ្ណនោះថា ពេលកងទ័ពយួន អមដោយទាហានខ្មែរខ្លះផងចូលដល់ក្នុងទីក្រុងភ្នំពេញផ្តួលរំលំរបបប៉ុល ពត នៅថ្ងៃទី៧ មករា១៩៧៩ គេក៏បានទៅរកឃើញមាសប្រមាណ៤តោនរក្សាទុកនៅសេនាធិការរបស់ ប៉ុល ពត ។ មាសអស់ទាំងនោះត្រូវបានគាត់និយាយថា គេដាក់នៅក្នុងឡាំងគ្រាប់ ហើយក៏ត្រូវគេរឹបអូសយក។ មាសប្រមាណ៨តោនទៀតដែលពួកខ្មែរក្រហមបានប្រមូលពីពលរដ្ឋទូទៅទៅរំលាយជាដុំៗ ក៏ត្រូវបានទាហានយួន និងទាហានខ្មែរតាមដេញវាយដល់តំបន់តាសាញ់ ក្នុងស្រុកសំឡូត ហើយរឹបអូសយកជាមួយនឹងនាឡិកាប្រមាណ១៥០០គ្រឿង។ មាសអស់ទាំងនេះ ក៏ដូចជាពេជ្រ ដែលមានតម្លៃអស់ទាំងនេះ គេពុំបានឮមេដឹកនាំប្រទេស ពោលគឺមេដឹកនាំគណបក្សប្រជាជននិយាយរំលឹកម្តងណាប្រាប់ប្រជារាស្ត្រខ្មែរឡើយ នៅពេលដែលពួកគេបន្តកាន់អំណាចពីការលើកបន្តុបដោយយួនមក។**

**យ៉ាងណាក៏ដោយ គេនៅចាំបានថា កាលប្រមាណ១០ឆ្នាំមុននេះ លោក ប៉ែន សុវណ្ណ ក៏ធ្លាប់បាននិយាយរឿងនេះថា មាសអស់ទាំងនោះក្រោយពីមេដឹកនាំគណបក្សប្រជាជនបានអែបអបយួនកុម្មុយនីស្តក្រុងហាណូយ ឱ្យចាប់ខ្លួនគាត់យកទៅដាក់គុករយៈពេល១០ឆ្នាំ៥២ថ្ងៃនៅទីក្រុងហាណូយនោះ អំណាចត្រួតត្រារដ្ឋាភិបាលក៏បានធ្លាក់ទៅក្នុងដៃលោក ហ៊ុន សែន ។ហើយគាត់នោះគឺជាអ្នកទទួលខុសត្រូវលើកំណប់មាសពេជ្រទាំងអស់ជាសម្បត្តិជាតិទាំងនេះ គ្រាន់តែមិនដឹងថា តើអ្នកត្រួតត្រាគ្រប់គ្រងប្រទេសបានយកមាសពេជ្រអស់ទាំងនោះជាសម្បត្តិជាតិទៅបែងចែកឱ្យនរណាខ្លះ និងមានឱ្យមួយចំណែកទៅទាហានយួនដែរឬអត់។**

**មាសដល់ទៅប្រមាណជិត១៣តោន និងពេជ្រ២គីឡូក្រាម ដែលមានតម្លៃរាប់រយលានដុល្លារ។ ហើយបើគេយកលុយទាំងនោះធ្វើជាដើមទុននៃការរកស៊ីតាំងពីឆ្នាំ១៩៧៩រហូតមកដល់ពេលនេះ ក៏វាបង្កើតបាននូវគំនរទ្រព្យសម្បត្តិរាប់សែនលានដុល្លារឯណោះ។ សួរថាតើប្រទេសជាតិកម្ពុជាដែលបានធ្លាក់ក្នុងមហាវិនាសកម្ម ក៏ដូចជាប្រជារាស្ត្រខ្មែរដែលបានរងគ្រោះដោយនយោបាយ និងសង្គ្រាមកាប់សម្លាប់គ្នាមកនេះបានប្រយោជន៍អ្វីខ្លះពីសម្បត្តិមហាសាល ? ជាពិសេសតើពួកអ្នកត្រួតត្រាប្រទេសបានបែងចែកមាសពេជ្រអស់ទាំងនោះជាសម្បត្តិជាតិបាត់ទៅណាបានជាចេះតែនាំគ្នាសងំស្ងៀម ហើយក៏ឃើញតែពួកអ្នកកាន់អំណាចធំៗ និយាយឱ្យចំគឺមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកាន់តែមានឡើងៗនោះ ?**

**យ៉ាងណាក៏គេនៅនឹកឃើញការប្រកាសរបស់លោក ហ៊ុន សែន កាលប៉ុន្មានឆ្នាំមុន អួតសម្ញែងរបៀបបញ្ឆឺប្រជារាស្ត្រថា គណបក្សប្រជាជន និងរូបគាត់មានលុយចាយដល់ទៅ២០០ឆ្នាំទៀតមិនអស់។ តើគាត់បានទ្រព្យសម្បត្តិអស់នោះមកពីណា បើសូម្បីតែខ្លួនគាត់ ក៏ធ្លាប់បាននិយាយជាសាធារណៈថា មិនដែលចេះជប់លុយកាក់ម្តងណានោះ ? ហើយគំនរទ្រព្យសម្បត្តិអស់ទាំងនោះកើនឡើងតាមរបៀបណា បើសូម្បីតែទ្រព្យសម្បត្តិធនធានរបស់ប្រទេស ដូចជាព្រៃឈើ រ៉ែ ត្បូង មានតម្លៃអ្វីៗក៏ចេះតែបន្តពាយនៅក្រោមអំណាចដឹកនាំត្រួតត្រាប្រទេសរបស់គណបក្សប្រជាជន ជាពិសេសរបស់លោក ហ៊ុន សែន នោះ ?**

**រឿងមាសសុទ្ធប្រមាណជាង១២តោននិងពេជ្រ២គីឡូក្រាមពុំមែនជារឿងសាមញ្ញ ហើយក៏ពុំមែនអ្នកមានអំណាចអាចបិទបាំងឱ្យជិតរហូតនោះទេ។ ផ្ទុយទៅវិញគង់មានពេលណាមួយវានឹងក្លាយទៅជាបញ្ហាដែលនឹងបកអាក្រាតពួកមនុស្សទាំងឡាយណាដែលកឹបកេងប្រវ័ញ្ចទ្រព្យសម្បត្តិជាតិអស់ទាំងនេះ ហើយខំបំភ្លៃ បង្វែងប្រជារាស្ត្រមិនឱ្យយល់ដឹងតាមមធ្យោបាយផ្សេងៗនិងលទ្ធភាពផ្សេងៗដែលពួកគេមាននោះ។ ជាមួយគ្នានេះដែរ ក៏មានការងឿងឆ្ងល់ដែរថា ហេតុអ្វីបានជាគណបក្សប្រជាជន ហ៊ុន សែន ចេះតែមានទ្រព្យសម្បត្តិធនធានសំបូរហូរហៀរច្រើនឡើងៗ ហើយក៏តាំងខ្លួនធ្វើជាអ្នកចិត្តល្អបេះរំលែកលុយកាក់បន្តិចបន្តួចឱ្យប្រជារាស្ត្រក្រីក្រ ក៏ដូចជាទ្រព្យសម្បត្តិជាតិនិងជំនួយបរទេសទៅសាងសង់សមិទ្ធផលនានាហើយ ប្រកាសផ្សព្វផ្សាយថា ជាស្នាដៃរបស់ខ្លួន?**

**នេះអាចមកពីគណបក្សកាន់អំណាចរបស់លោក ហ៊ុន សែន មានការបារម្ភថា គង់មានថ្ងៃណាមួយប្រជារាស្ត្រដឹងថា អ្នកណាដឹកនាំប្រទេស ហើយលួចទ្រព្យសម្បត្តិធនធានរបស់ជាតិ ដូច្នេះប្រជារាស្ត្រនឹងមិនអត់ឱនឱ្យ ហើយនោះ គឺជាអ្វីដែលលោកហ៊ុន សែន ធ្លាប់បាននិយាយរំលឹកថាអំណាចរបស់ប្រជារាស្ត្រដែលគាត់តែងតែមានការភិតភ័យហើយបញ្ចេញការគំរាមម្តងៗនោះ។**

**ប្រាកដណាស់ថា នៅពេលដែលកម្ពុជាក្លាយទៅជាប្រទេសនីតិរដ្ឋពិតប្រាកដនោះ ពួកអ្នកលួចមាសពេជ្រជាសម្បត្តិជាតិទាំងនេះ នឹងមិនអាចលាក់មុខ ហើយអាចរួចខ្លួនពីអំណាចច្បាប់របស់សង្គម បាននោះទេ៕**